ព្រះ រាជា ណា ច ក្រ កម្ពុ ជា
ជា តិ សា ស នា ព្រះ ម ហា ក្ស ត្រ

អគ្គិសនីកម្ពុជា
លេខ: ០០៣៦ សដណ·អគរប

សេចក្តីជូនដំណឹង
ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជាត្រូវការជ្រើសរើស**បុគ្គលិក** ដើម្បីចូលបម្រើការងារនៅតាមបណ្តាអនុស្ថានីយ អង្គភាពបណ្តាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **<u>លក្ខណៈសម្បត្តិបេក្ខជន</u>** :

- **បុគ្គលិកប្រចាំការអនុស្ថានីយព្រែកប្រសព្វ**(ខេត្តក្រចេះ)	ចំនួន០៨រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយមណ្ឌលគិរី**	ចំនួន០៧រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយទី១០**(Minebea កំបូល)	ចំនួន០១រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយកំពង់ឆ្នាំង**(CPG)	ចំនួន០១រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយតាតៃ**(ខេត្តកោះកុង)	ចំនួន០១រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយរតនមណ្ឌល**(ខេត្តបាត់ដំបង)	ចំនួន០២រូប
- **បុគ្គលិកប្រចាំការអនុស្ថានីយអូរសោម**(ខេត្តពោធិ៍សាត់)	ចំនួន០៥រូប
	សរុបចំនួន២៥រូប :

+បេក្ខជនភេទប្រុស មានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ
+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធE.III.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
+កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ

*- **<u>បញ្ជាក់</u>** : បេក្ខជនគ្រប់ខេត្ត-ក្រុង ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមីប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺផ្តល់អាទិភាពជូន ។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។**

*- **បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកជាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនច្បាប់ដើមមកជាមួយ។ ករណីបេក្ខជនមិនបានអញ្ជើញមកជាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជាមិនទទួលពាក្យជូនឡើយ។**

*- **បេក្ខជនជាក់ពាក្យត្រូវពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពឲ្យបានត្រឹមត្រូវ។**

*- **<u>បេក្ខជនត្រូវមកជាក់ពាក្យ និងភ្ជាប់មកជាមួយនូវ</u>** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា	ចំនួន០១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦	ចំនួន០១ច្បាប់
- កិច្ចសន្យាសម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ	ចំនួន០១ច្បាប់
- សលាកប័ត្របេក្ខជន	ចំនួន០១ច្បាប់

- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន០១ច្បាប់
- តារាងពិន្ទុ(TRANSCRIPT) ចំនួន០១ច្បាប់
- ច្បាប់ដើម និងច្បាប់ចម្លង នៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ចំនួន០១ច្បាប់

*** - ចំពោះបែបបទមួយចំនួនទៀតដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់មានកាតព្វកិច្ចបំពេញបន្ថែម។**

*** - ទីកន្លែងទទួលពាក្យ : សាលប្រជុំនាយកដ្ឋានរដ្ឋបាល នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា(អតីតរោងចក្រអគ្គិសនីទី៤)។**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ រៀងរាល់ថ្ងៃធ្វើការ

- **<u>ពេលព្រឹក</u>** ចាប់ពីម៉ោង០៨:០០ ដល់ម៉ោង១១:៣០ **<u>ពេលល្ងាច</u>** ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០

*** - <u>ព័ត៌មានផ្សេងៗ</u>**:សូមអញ្ជើញមកទាក់ទងការិយាល័យរដ្ឋបាលទីស្នាក់ការកណ្តាលអគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ គ្រប ១៧កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១

ស.រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកអគ្គិសនីកម្ពុជា

អគ្គនាយក

អេង_គង្គា

<u>បញ្ជាក់</u>

- សេចក្តីជូនដំណឹងនេះ: ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។